# ប្រភពនៃទស្សនវិជ្ជាអប់រំ៖ ការអភិវឌ្ឍនិយម និងការរិះគន់និយម


ដោយ៖ **បណ្ឌិត សូ សុធីរ**

មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ

វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

រាជបណ្ឌិត្យសភាកម្ពុជា


## សេចក្តីផ្តើម

*ក្នុងផ្នែកដូចតទៅ យើងនឹងពិនិត្យមើលទ្រឹស្តីអប់រំពីរ គឺការអភិវឌ្ឍនិយមនិងរិះគន់និយម។ ដោយហេតុថា ទស្សនវិជ្ជាទាំងឡាយរាប់បញ្ចូលបរមត្ថវិទ្យា ពុទ្ធិវិទ្យា វិទ្យាសាស្ត្រសីលធម៌ និងតក្កវិទ្យានោះ ទ្រឹស្តីទាំងឡាយស្វែងរកការពន្យល់បាតុភូត និងលំនាំដែលមានលក្ខណៈពិសេសជាងមុន។ ទ្រឹស្តីអប់រំពន្យល់ពីតួនាទី និងមុខងារនៃសាលារៀន កម្មវិធីសិក្សា ការបង្រៀន និងការសិក្សា។ ទ្រឹស្តីមួយចំនួនបានបង្កើតចេញពីទស្សនវិជ្ជា ហើយមួយចំនួនផ្សេងទៀត កើតចេញពីការប្រតិបត្តិ។*

## ១-ការអភិវឌ្ឍនិយម (Progressivism)

### ក-ចលនាកែទម្រង់ជាសកល

*ការអប់រំតាមបែបអភិវឌ្ឍ គឺជាផ្នែកមួយនៃការកែទម្រង់ជាសកល ក្នុងជីវិតអាម៉េរិក នៅចុងសតវត្សរ៍ទី១៩ និងដើមសតវត្សរ៍ទី២០។ ទោះជាញឹកញាប់ វាបានផ្សារភ្ជាប់គ្នាជាមួយពិសោធន៍និយមរបស់លោក* Jonh Dewey *ក៏ដោយ ក៏ចលនាការអប់រំបែបអភិវឌ្ឍនិយម បានវេញត្បាញបញ្ចូលគ្នានូវខ្សែផ្សេងៗ។ ដោយហេតុថា ការអភិវឌ្ឍមួយចំនួនស្វែងរកប្រើប្រាស់ការអប់រំ សម្រាប់ការកែទម្រង់សង្គមនោះ ការអភិវឌ្ឍផ្សេងទៀត ជាពិសេស អ្នករដ្ឋបាលបានផ្តោតអារម្មណ៍ទៅលើការបង្កើតសាលារៀនឱ្យមានសមត្ថភាពជាងមុន និង ចំណាយឱ្យមានប្រសិទ្ធភាពជាងមុន។ ការអភិវឌ្ឍផ្នែករដ្ឋបាល ស្វែងរកការស្ថាបនាឱ្យបានទូលំទូលាយជាងមុន ដែលអាចធ្វើឱ្យថ្នាក់រៀនបានចម្រើនជាងមុន និង បង្កើតកម្មវិធីសិក្សាផ្សេងៗគ្នា*[1]*។ ការអប់រំបែបអភិវឌ្ឍកើតចេញពីការប្រឆាំងនឹងការសិក្សាបែប*

[1] Arthur Zilversmith, *Changing Schools: Progressive Theory and Practice, 1930-1960* (Chicago: University of Chicago Press, 1993).

ប្រពៃណី។ គរុវិទូ ដូចជាលោក G. Stanley Hall, Francis Parker, and William H. Kilpatrick បានពោលអាងប្រឆាំងនឹងទម្រង់ការដែលមិនត្រូវការបញ្ញា ការទន្ទេញដដែលៗ និងការគ្រប់គ្រងថ្នាក់រៀនបែបផ្តាច់ការ។ គ្រូបង្រៀនបែបអភិវឌ្ឍនិយមបានអភិវឌ្ឍបែបបទនិងវិធីបង្រៀន ដែលសង្កត់ធ្ងន់ទៅលើចំណូលចិត្ត និងតម្រូវការសិស្ស។ ថ្នាក់រៀនរបស់ពួកគេមានភាពបត់បែន បណ្តោយតាមចិត្ត និងបើកចំហ។

**១-១-បញ្ញត្តិជាគន្លឹះ**

**ក-ការប្រតិបត្តិដែលគាំទ្រការអភិវឌ្ឍ**

សមាគមអប់រំបែបអភិវឌ្ឍ (The Progressive Education Association) ជាអង្គការមួយ ដែលរួមបញ្ចូលពីទស្សនៈផ្សេងនោះ មិនបានធ្វើឱ្យទស្សនវិជ្ជាអប់រំមានភាពទូលំទូលាយទេ ពីព្រោះគរុវិទូបែបអភិវឌ្ឍ ជាញឹកញាប់មិនបានយល់ស្របក្នុងចំណោមពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ជាទូទៅ គេបានថ្កោលទោសការប្រតិបត្តិសាលារៀនតាមប្រពៃណីដូចតទៅ៖

១-គ្រូបង្រៀនដែលប្រើអំណាចផ្តាច់ការ (Authoritarian teacher)។

២-ការបង្រៀន ដែលពឹងផ្អែកតែទៅលើសៀវភៅ (Book-based instruction)។

៣-ការទន្ទេញចាំមាត់បែបអកម្មនៃព័ត៌មានពិត (Passive memorization of factual information)។

៤-ការផ្តាច់សាលាចេញពីសង្គម (The isolation of school from society)។

៥-ការប្រើការបង្ខិតបង្ខំតាមបែបចិត្តសាស្ត្រ និងរាងកាយ ដើម្បីគ្រប់គ្រងថ្នាក់រៀន (Using physical and psychological coercion to manage classrooms)។

ទោះបីជាពួកគេមានការលំបាកខ្លាំងជាងក្នុងការយល់ព្រម អំពីអ្វីដែលគេពេញចិត្តក៏ដោយ ក៏សមាជិកនៃសមាគមគ្រូបង្រៀនបែបអភិវឌ្ឍជាទូទៅ ជឿជាក់ថា៖

១-កុមារគួរតែមានសេរីភាព ដើម្បីអភិវឌ្ឍតាមធម្មជាតិ។

២-ចំណូលចិត្ត ដែលត្រូវបានក្រោចដោយបទពិសោធផ្ទាល់នោះ គឺជារំញោចដ៏ប្រសើរបំផុតសម្រាប់ការសិក្សា។

៣-គ្រូបង្រៀនគួរតែជួយសម្រួលដល់ការសិក្សា។

៤-សហប្រតិបត្តិការជិតស្និទ្ធ មានសារៈសំខាន់បំផុត រវាងសាលារៀននិងគ្រួសារ។

៥-សាលារៀនដែលមានការអភិវឌ្ឍ គួរតែជាមន្ទីរពិសោធន៍ សម្រាប់ធ្វើការពិសោធ។

### ខ-កំណែទម្រង់បែបអភិវឌ្ឍ នៅតាមសាលារៀន

*ដោយប្រឆាំងជំទាស់នឹងកម្មវិធីសិក្សាតាមកម្មវត្ថុមុខវិជ្ជាជម្មតានោះ អភិវឌ្ឍន៍វិទូបានធ្វើពិសោធន៍ជាមួយនឹងកម្មវិធីសិក្សាផ្សេងគ្នា ការប្រើប្រាស់សកម្មភាពទាំងឡាយបទពិសោធ ការដោះស្រាយបញ្ហា និងគម្រោងការផ្សេងៗ។ គ្រូបង្រៀនតាមបែបអភិវឌ្ឍសិស្សមជ្ឈមណ្ឌលក៏បានសង្កត់ធ្ងន់ទៅលើការសិក្សាបែបសហការ ជាជាងការប្រកួតប្រជែង។ អភិវឌ្ឍន៍វិទូ ដែលបានតម្រង់ទិសផ្នែកសង្គមច្រើនជាងនោះ ដែលត្រូវបានគេហៅថា អ្នកស្ថាបនាសង្គមឡើងវិញ បានស្វែងរកបង្កើតមជ្ឈមណ្ឌលសាលារៀន នៃការកែទម្រង់ផ្នែកសង្គមធំជាងមុន[2]។ ជាងនេះទៀត សាលារៀនបែបអភិវឌ្ឍ ជាពិសេសផ្នែកឯកជនបានស្វែងរកផ្តល់សេរីភាពដល់កុមារពីសេចក្តីអត់ធ្មត់ និងការទប់តាមជម្មតា។*

### ១-២-សំណួរជាមូលដ្ឋាន

### ក-ការប្រឆាំងនឹងប្រពៃណី

*អភិវឌ្ឍន៍វិទូ មិនចូលចិត្តសិទ្ធាន្ត និងមិនឆ្លើយតបទៅនឹងសំណួរអំពីចំណេះដឹងការអប់រំ សាលារៀន ការបង្រៀន និងការសិក្សាដោយមានសំឡេងតែមួយទេ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងន័យជាទូទៅ អភិវឌ្ឍន៍វិទូ យល់ឃើញថា ចំណេះដឹងជាបទពិសោធមនុស្ស ដែលមានទំនាក់ទំនងនឹងគ្នា ជាជាងក្នុងន័យជាសកល។ ការអប់រំ គឺជាមធ្យោបាយមួយនៃការបញ្ចេញប្រតិដ្ឋញាណរបស់មនុស្សតាមការគិត និងការទទួលអារម្មណ៍។ អភិវឌ្ឍន៍វិទូ ជឿជាក់ថា កុមារទាំងអស់មានសិទ្ធិទៅរៀន។*

### ខ-កំណែទម្រង់វិទូផ្នែកសង្គម និងផ្នែកសិស្សមជ្ឈមណ្ឌល

*ទោះបីជាបានរួបរួមគ្នា ដើម្បីប្រឆាំងនឹងប្រពៃណីនិយម និងផ្តាច់ការនិយមក៏ដោយ ក៏អភិវឌ្ឍន៍វិទូ បានសង្កត់ធ្ងន់ទៅលើសេរីភាពកុមារ ហើយអ្នកផ្សេងទៀត សង្កត់ធ្ងន់ទៅលើកំណែទម្រង់សង្គម។ អភិវឌ្ឍន៍វិទូផ្នែកសិស្សមជ្ឈមណ្ឌល ចង់ឱ្យសាលារៀនដែលក្នុងនោះ កុមារ មានសេរីភាព ដើម្បីធ្វើពិសោធន៍ លេង និងបង្ហាញអារម្មណ៍ពីខ្លួនគេ។ អភិវឌ្ឍន៍វិទូផ្នែកកំណែទម្រង់សង្គម ចង់ឱ្យសាលារៀនធ្វើជាភ្នាក់ងារនៃការផ្លាស់ប្តូរផ្នែកសង្គម។*

### គ-ភាពត្រៀមជាស្រេច ចំណូលចិត្ត និងតម្រូវការ

*ចំពោះអភិវឌ្ឍន៍វិទូនិយម ភាពត្រៀមខ្លួនជាស្រេចរបស់កុមារ និងចំណូលចិត្ត និងមិនមែនជាប្រធានបទ ដែលបានកំណត់ជាមុន*

[2] The definitive history of progressive education remains Lawrence A. Cremin, *The Transformation of the School* (New York: Random Handom House, 1961).

បង្កើតកម្មវិធីសិក្សានិងការបង្រៀន។ គ្រូបង្រៀនតាមបែបអភិវឌ្ឍ ដែលចេះបត់បែនការបង្រៀនប្រើប្រាស់លទ្ធភាព នៃសកម្មភាពសិក្សា ដូចជាការដោះស្រាយបញ្ហា ដំណើរកម្សាន្តសិក្សា ការបង្ហាញអារម្មណ៍បែបសិល្បៈ ប្រតិដ្ឋ និងគម្រោងការផ្សេងៗ។ ពួកគេមើលឃើញការបង្រៀន និងការសិក្សាថាជាលំនាំសកម្ម គួរឱ្យរំភើបចិត្ត និងមានការផ្លាស់ប្តូរ។

### ឃ-ការស្ថាបនាតថភាព

ក្នុងនាមជាអ្នកស្ថាបនាសហគមន៍អប់រំនោះ គ្រូបង្រៀនបែបអភិវឌ្ឍ ចង់ឱ្យសិស្សសិក្សាតាមបែបសហការទៅលើគម្រោងផ្សេងៗ ដោយពឹងផ្អែកទៅលើបទពិសោធរួមរបស់គេ។ គោលវិធីនេះ មានភាពស្រដៀងគ្នា ទៅនឹងគោលវិធីស្ថាបនានិយមដ៏មានប្រជាប្រិយ។ ស្ថាបនានិយមដូចជាអភិវឌ្ឍនិយម សង្កត់ធ្ងន់ទៅលើការសិក្សាតាមការប្រតិបត្តិ និងអន្តរកម្ម ដែលក្នុងនោះសិស្ស សិក្សាតាមបែបសហការ ដើម្បីពង្រីក និងពិនិត្យ កែតម្រូវមូលដ្ឋានចំណេះដឹងរបស់គេ[3]។

## ១-៣-ការអនុវត្ត សម្រាប់ក្រុមរៀនទទួលបន្ទុកថ្នាក់នាពេលសព្វថ្ងៃ

### ក-គំរូនៃល្បិចអភិវឌ្ឍ

តើល្បិចអភិវឌ្ឍ អាចដំណើរការក្នុងសាលារៀនសព្វថ្ងៃបែបណា? ថ្នាក់រៀនសិក្សាសង្គមនៅអនុវិទ្យាល័យ អាចពិនិត្យមើលការរួមចំណែករបស់ពួកឡាតាំង ចំពោះជីវភាពរស់នៅសម្រាប់ប្រជាជនអាម៉េរិក។ ក្រោយពេលកំណត់ន័យពាក្យឡាតាំង និងការកំណត់អត្តសញ្ញាណក្រុមជាតិពន្ធុផ្សេងៗ (Ethnic groups) ដែលបានរាប់បញ្ចូលក្នុងការជ្រើសរើសទុកជាមុននោះ ថ្នាក់រៀន អាចត្រូវបានបែងចែកទៅជាក្រុមស្រាវជ្រាវ និងក្រុមរាយការណ៍។ ក្រុមនីមួយៗនឹងផ្តោតអារម្មណ៍ ទៅលើក្រុមឡាតាំង (ក្រុមជាតិពន្ធុដូចជា ព័រតូរីកូអាម៉េរិក (Puerto Rican Americans), គុយបាអាម៉េរិក (Cuban Americans) និងក្រុមជាតិពន្ធុ១៥ក្រុមទៀត ដែលមានដើមកំណើតចេញពីជនជាតិអេស្ប៉ាញ) ពិសេស និងត្រៀមរបាយការណ៍ ដែលនឹងត្រូវបានបែងចែកតាមបែបសហការជាមួយសិស្សក្នុងថ្នាក់រៀន។ សកម្មភាពរបស់ក្រុមអាចរាប់បញ្ចូលដូចតទៅៈ

ក្រុម **ក** នឹងតាមដានដើមកំណើត ការផ្លាស់ប្តូរលំនៅតំបន់នៃនិវាសនដ្ឋានចម្បងៗ និងបញ្ហានៃជនជាតិអាម៉េរិក ដើមកំណើតម៉ិកស៊ិក។

ក្រុម **ខ** នឹងដឹកនាំការស្រាវជ្រាវស្រដៀងគ្នាទៅលើក្រុមព័រតូរីកូអាម៉េរិក។

ក្រុម **គ** នឹងធ្វើដូចគ្នាទៅលើក្រុមគុយបាអាម៉េរិក។ ក្រុមទាំងឡាយនឹងត្រូវបាន

[3] For a discussion of the challenges of translating constructivist epistemology into classroom practice, see Peter W. Airasian and Mary E. Walsh, ''Constructivist Cautions,'' *Phi Delta Kappan* (February 1997), pp. 444-449.

លើកទឹកចិត្ត ដើម្បីបង្កើតរបាយការណ៍ពហុវិសាលភាព (របាយការណ៍រួមក្រុមទាំង៣ខាងលើ) ដែលប្រើប្រាស់សម្ភារៈបោះពុម្ព ភាពយន្ត ការពន្យល់ដោយរូបភាព និងអញ្ជើញវាគ្មិន ដែលជាតំណាងក្រុមពិសេស។ បន្ទាប់មកក្រុមទាំងមូល ដែលក្នុងនាមជាបទពិសោធសិក្សាតាមបែបសហការនោះ នឹងប្រើប្រាស់របាយការណ៍ក្រុមដើម្បីកំណត់អត្តសញ្ញាណភាពដូចគ្នា និងភាពខុសគ្នាខាងវប្បធម៌ រវាងក្រុមជាតិពន្ធុទាំង៣ និងការរួមចំណែករបស់សង្គមអាម៉េរិក។

គ្រូបង្រៀន គួរតែធ្វើសកម្មភាពនៅក្នុងនាមជាអ្នកសម្របសម្រួលខាងធនធាន នៅក្នុងគម្រោងផែនការ។ តាមការប្រឹក្សាជាមួយក្រុមនីមួយៗគាត់នឹងផ្តល់យោបល់ឱ្យទៅបណ្ណាល័យអ៊ិនធឺណិត និងប្រភពធនធានពីសហគមន៍ និងជួយសិស្សរកឃើញមធ្យាបាយ ផ្សេងៗ នៃការស្រាវជ្រាវទៅតាមគម្រោង និងដោះស្រាយបញ្ហា ដែលវាបានបង្ហាញ។ គ្រូគួរតែដឹកនាំសិស្សផងដែរ ក្នុងការបែងចែកព័ត៌មាន និងឈានទៅដល់ការសន្និដ្ឋានតាមបែបសហការ។

## ២-ទ្រឹស្តីបែបរិះគន់ ( Critical Theory )

ទ្រឹស្តីតាមបែបរិះគន់ ដែលជាទ្រឹស្តីនៃការអប់រំសម័យទំនើប ដ៏មានឥទ្ធិពលកម្រិតខ្ពស់នោះ ជំរុញឱ្យមានការរិះគន់ តាមការវិភាគយ៉ាងហ្មត់ចត់នៃសាលារៀន និងសង្គម ដើម្បីលាតត្រដាងទំនាក់ទំនងអំណាច តាមបែបកេងប្រវ័ញ្ច និងនាំមកដល់សមភាពភាពត្រឹមត្រូវ និងយុត្តិធម៌។ ការប៉ាន់ស្មានតាមទ្រឹស្តីជាច្រើន កើតចេញពីទស្សនវិជ្ជាបែបអត្ថិភាពនិយម និងសម័យក្រោយទំនើបនិយម ម៉ាក្សស៊ីស្តនិយមបែបថ្មី ទ្រឹស្តីពហុវប្បធម៌និងស្ត្រីនិយម ហើយនិងគរុកោសល្យសេរីរបស់លោក Paulo Freire។ ក្នុងចំណោមអ្នកដឹកនាំដែលបានបង្ហាញខ្លួនកម្រិតខ្ពស់នៃទ្រឹស្តីរិះគន់និយមគឺ Henry Giroux និង Peter McLaren។

### ២-១-បញ្ញត្តិជាគន្លឹះ

### ក-ឥទ្ធិពលម៉ាក្សស៊ីស្តបែបថ្មី

ទ្រឹស្តីបែបរិះគន់ ត្រូវបានទទួលឥទ្ធិពលតាមមនោគមវិជ្ជា កាលម៉ាក្ស (Karl Marx) ដែលជាទស្សនវិទូនាសតវត្សរ៍ទី១៩ ដ៏សំខាន់ម្នាក់ ដែលបានអះអាងថា ស្ថាប័នទាំងអស់ពឹងផ្អែកទៅលើមូលដ្ឋានសេដ្ឋកិច្ច ហើយប្រវត្តិសាស្ត្រមនុស្ស ជាការតស៊ូ ដើម្បីវណ្ណៈសេដ្ឋកិច្ចសង្គម សម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងសង្គម[4]។ ជាញឹកញាប់ ទ្រឹស្តីវិទូបែបរិះគន់ប្រើប្រាស់បញ្ញត្តិ តាមទ្រឹស្តីម៉ាក្សដូចជាទំនាស់វណ្ណៈ និងភាពបែកបាក់។ ភាពបែកបាក់គ្នានិយាយយោងដល់សភាពបែបចិត្តសាស្ត្រ និង

[4] For an assessment of Marxist education theory, see Frank Margonis, “Marxist, Liberalism, and education Theory, *Educational Theory* (Fall 1993), pp. 449-465.

សង្គម នៃមនុស្សដែលត្រូវបានគេចាត់ទុកថា មិនសំខាន់ និងត្រូវបានជំរុញដល់មនុស្ស ទ្រនាប់សង្គម។

### ខ-ក្រុមដ៏មានឥទ្ធិពល មានចំនួនច្រើនជាង

ដោយយោងទៅតាមទ្រឹស្តីវិទូបែបរិះគន់ មនសិការបែបរិះគន់ ទាមទារនូវការទទួលបានពុទ្ធិ ដែលជាវណ្ណៈសង្គមរបស់បុគ្គល ដោយរាប់បញ្ចូលទាំងសេចក្តីសង្ឃឹម និងឱកាស ផ្នែកសេដ្ឋកិច្ច និងសង្គមនោះ គឺត្រូវមានលក្ខខណ្ឌតាមជាតិសាសន៍ សមធម៌ភេទ និងវណ្ណៈ។ វណ្ណៈសេដ្ឋកិច្ចសង្គមខ្ពស់ជាង និងគ្រប់ដណ្តប់ ដែលគ្រប់គ្រងស្ថាប័នអប់រំ សេដ្ឋកិច្ច នយោបាយ និងសង្គម ប្រើប្រាស់ឥទ្ធិពល ដើម្បីរក្សា ឬបង្កើតឡើងវិញនូវតំណែងដោយគួរពេញចិត្ត និងដើម្បីទុកជាភាពបន្ទាប់បន្សំនូវវណ្ណៈ ដែលមិនមានប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងស ង្គម[5]។

នៅក្នុងសហរដ្ឋអាមេរិក ក្រុមដែលនៅក្រោមបង្គាប់ជាប្រវត្តិសាស្ត្រ គឺក្រុមនៅតំបន់ជាយក្រុងនិងអ្នកក្រ នៅជនបទ ពួកអាមេរិកដើមកំណើតអាហ្វ្រិក និងជនជាតិដើមឡាតាំង ស្រី ប្រុស និងស្រីរួមភេទដូចគ្នា[6]។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈការអប់រំបែបរិះគន់វណ្ណៈ និងក្រុម ដែលនៅក្រោមបង្គាប់ អាចដឹងពីការកេងប្រវ័ញ្ចរបស់គេ ប្រឆាំងនឹងការគាបសង្កត់ បដិសេធគំរូនៃការជិះជាន់ និងផ្តល់អំណាចដោយខ្លួនឯង។

### ២-២-សំណួរជាមូលដ្ឋាន

### ក-ទស្សនវិជ្ជាសាធារណៈថ្មីមួយ

ដោយបានទាក់ទាញឥទ្ធិពលដ៏ធំធេងពីទស្សនវិទូសម័យក្រោយទំនើបនិយម ដែលបានរៀបរាប់ពីមុនក្នុងជំពូកនេះ ទ្រឹស្តីវិទូបែបរិះគន់ ចង់សរសើរមនសិការអំពីបញ្ហា ដែលពាក់ព័ន្ធនឹងចំណេះដឹង ការអប់រំ សាលារៀន ការបង្រៀន និងរៀន។ គេជឿជាក់ថា ចំណេះដឹង គឺជាបញ្ហានៃអំណាច និងការគ្រប់គ្រងផ្នែកអប់រំ សេដ្ឋកិច្ច នយោបាយ និងសង្គម។ ជាពិសេស ទ្រឹស្តីវិទូបែបរិះគន់ចង់សរសើរដល់មនសិការនៃអ្នកទាំងឡាយ ដែលត្រូវបានគេជំរុញឱ្យកាន់តំណែង ដែលនៅក្រោមបង្គាប់ក្នុងសង្គម ដោយសារតែជាតិសាសន៍ ក្រុមជនជាតិ ភាសា វណ្ណៈ ឬសមធម៌ភេទ[7]។

---

[5] Martin Carnoy, ''Education, State, and Culture in American Society,'' in Henry A. Giroux and Peter L. Mclaren, eds., *Critical Pedagogy, the State, and Cultural Struggle* (Aldany: State University of New York Press, 1998), pp.6-7

[6] Angeline Martel and Linda Peterat, ''Margins of Exclusion, Margins of Transformation: The Place of Women in Education, '' in Rebecca A. Martusewicz and William Reynold, eds., *Inside/ Out: Contemporary Critical Perspectives in Education* (New York: St. Martin's Press, 1994),pp. 151-154.

[7] Henry A. Giroux and Peter L. McLaren, ''Schooling, Cultural Politics, and the Struggle for Democracy, ''in Henry A. Giroux and Peter McLaren, eds., *Critical Pedagogy, the State, and Cultural Struggle* (New York: State University of New York Press, 1989),pp. xi-xii.

## ខ-ការគ្រប់គ្រងសង្គម

ទ្រឹស្តីវិទូបែបរិះគន់អះអាងថា វណ្ណៈដ៏សំខាន់តាមបែបសង្គម នយោបាយ សេដ្ឋកិច្ច ត្រួតពិនិត្យ និងប្រើប្រាស់សាលារៀន សម្រាប់ការថែរក្សា និងត្រួតពិនិត្យសង្គម។ ដើម្បីថែរក្សាស្ថានភាពដដែល ដែលផ្តល់ឱ្យពួកគេនូវតំណែងដែលត្រូវការនោះ កុមារនៃវណ្ណៈសំខាន់ៗ ចូលសិក្សា នៅតាមស្ថាប័នអប់រំប្រកបដោយភាពថ្លៃថ្នូរ ហើយទទួលការអប់រំ ដែលរៀបចំពួកគេ សម្រាប់មុខរបរកម្រិតខ្ពស់ខាងជំនួញ ឧស្សាហកម្ម និងរដ្ឋាភិបាល។ កុមារស្ថិតក្នុងវណ្ណៈ និងក្រុមក្រោមការគ្រប់គ្រងរបស់គេ ត្រូវបានអប់រំឱ្យទទួលយកលក្ខខណ្ឌដែលដកហូតអំណាចរបស់ពួកគេ ថាជាពិភពដ៏ប្រសើរបំផុត។ ជាឧទាហរណ៍ សាលារៀននៅតំបន់ជាយក្រុង ដែលមិនបានផ្តល់ប្រយោជន៍ខាងសេដ្ឋកិច្ច និងការធ្វើឱ្យចុះអន់ថយនៅតំបន់ជនបទនោះ បម្រើតែអ្នកក្រ ជនជាតិអាម៉េរិកដើមកំណើតអាហ្វ្រិក និងឡាតាំង។ ដោយមិនបានផ្តល់ហិរញ្ញវត្ថុគ្រប់គ្រាន់ ជាញឹកញាប់សាលារៀនទាំងនេះ ជាកន្លែងដែលមានអគារ មិនសមរម្យ និងខ្វះខាតធនធានចាំបាច់។

## គ-ការផ្តល់អំណាចដល់គ្រូ

សាលារៀននៅក្នុងក្រុង និងសាលារៀនជាច្រើនផ្សេងទៀតផងដែរ មានការជាប់ពាក់ព័ន្ធទៅនឹងការិយាធិបតេយ្យអប់រំយ៉ាងច្រើន។ ស្ថិតក្នុងសាលារៀនមួយ គ្រូបង្រៀនទាំងឡាយ ហាក់ដូចជាត្រូវបានផ្តាច់ចេញពីគេក្នុងថ្នាក់រៀនខ្លួនឯង។ ជាងនេះទៀត មាតាបិតា និងអ្នកផ្សេងទៀត នៅក្នុងសហគមន៍មូលដ្ឋានត្រូវបានរក្សាឱ្យនៅចម្ងាយមួយ ដោយមានការពាក់ព័ន្ធ និងអន្តរកម្មតិចតួចជាមួយសាលារៀន។ កម្មវិធីសិក្សាផងដែរ ត្រូវបានកំណត់ដោយអ្នករដ្ឋបាលកម្រិតខ្ពស់ជាង ដោយមានកន្លែងតូចមួយសម្រាប់អ្នកផ្តួចផ្តើមនៅមូលដ្ឋាន ដែលពាក់ព័ន្ធដល់បទពិសោធជីវិតរបស់សិស្សឬមនុស្សក្នុងសហគមន៍។

## ឃ-កម្មវិធីសិក្សាជាផ្លូវការ

ទ្រឹស្តីវិទូបែបរិះគន់ មើលឃើញកម្មវិធីសិក្សា ថាមានអត្ថិភាពក្នុងវិស័យពីរ គឺកម្មវិធីសិក្សាជាផ្លូវការ (Formal official curriculum) និងកម្មវិធីសិក្សាបែបលាក់កំបាំង។ កម្មវិធីសិក្សា ដែលមានអាណត្តិជាផ្លូវការ មានផ្ទុកដោយបំណិន និងមុខវិជ្ជាដែលត្រូវបង្រៀនទៅតាមគោលបំណងនិងត្រូវបានផ្ទេរទៅឱ្យសិស្សទាំងឡាយ។ កម្មវិធីសិក្សាបែបលាក់កំបាំង (Hidden curriculum) បង្ហាញឱ្យឃើញអាកប្បកិរិយា និងឥរិយាបថ ដែលត្រូវបានបង្ហាំទៅលើសិស្ស តាមរយៈមជ្ឈដ្ឋានសាលារៀន។ ទ្រឹស្តីវិទូបែបរិះគន់ ផ្តល់យោបល់ថា កម្មវិធីសិក្សាទាំងពីររក្សាឱ្យមានឋានៈវណ្ណៈសង្គមដ៏សំខាន់។

ថ្នាក់រៀនដ៏សំខាន់ ប្រើប្រាស់កម្មវិធីសិក្សាជាផ្លូវការ ដើម្បីផ្ទេរជំនឿ និងតម្លៃពិសេស ដែលជាកំណែប្រែថ្មី តាមធម្មានុរូប (Legitimate) នៃចំណេះដឹងសម្រាប់សិស្ស។ ឧទាហរណ៍ កំណែប្រែថ្មីនៃប្រវត្តិសាស្ត្រជាផ្លូវការពិពណ៌នាពីបទពិសោធជនជាតិអាម៉េរិក ដែលទទួលជ័យជម្នះ ក្នុងការតាំងទីលំនៅ និងការធ្វើឧស្សាហូបនីយកម្ម។ ជនជាតិអាម៉េរិកដើមកំណើតអាហ្វ្រិក និងជនជាតិដើមព្រមទាំងពួកឡាតាំង ត្រូវបានដាក់ជាជន ដែលទាក់ទងទៅនឹងនិទានកថាជាផ្លូវការ។ ទ្រឹស្តីវិទូបែបរិះគន់ គូសបញ្ជាក់ថាវិធីបង្រៀនដ៏ពេញចិត្តជាងគេរបស់សាលារៀនជាច្រើន គឺត្រូវប្រើប្រាស់សៀវភៅសិក្សា ដែលបានអនុម័តជាផ្លូវការ (Official sanctioned textbooks) ដើម្បីផ្ទេរព័ត៌មាន ដែលបានកែលម្អរួចហើយទៅឱ្យសិស្សៗជំនួសឱ្យការគិត និងការវិភាគដ៏ល្អិតល្អន់ លំនាំនៃការផ្ទេរព័ត៌មាន បង្កើតឡើងវិញក្នុងខ្លួនសិស្ស នូវចំណេះដឹងថ្មីជាផ្លូវការ។

### ខ-កម្មវិធីសិក្សាបែបលាក់កំបាំង

ជាតុជាគន្លឹះមួយក្នុងការគ្រប់គ្រងសង្គម ដោយផ្អែកទៅលើសាលារៀន ត្រូវបានផ្ទុកជាកម្មវិធីសិក្សាបែបលាក់កំបាំង។ លាក់កំបាំង ពីព្រោះវាមិនត្រូវបានអះអាង តាមការអះអាងជាសាធារណៈនូវអាណត្តិ ឬគោលនយោបាយសាលារៀន នៅតាមមូលដ្ឋាន វាបានជ្រួតជ្រាប នៅក្នុងមជ្ឈដ្ឋានសាលារៀនសាធារណៈ។

ឧទាហរណ៍ ឥរិយាបថតាមភេទ ដែលមនុស្សប្រុសមានភាពប្រសើរជាងមនុស្សស្រីខាងមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ រក្សានូវគំរូដាក់លាក់ខាងសមធម៌ភេទ ដែលអាចបន្តការអប់រំ និង មុខរបរក្នុងវិស័យទាំងនោះ។

ទោះបីជាថ្នាក់រៀនដែលត្រូវបានផ្តល់អភ័យឯកសិទ្ធិ មាននៅក្នុងសាលារៀនសំខាន់ៗជាប្រវត្តិសាស្ត្រក៏ដោយ ក៏ទ្រឹស្តីវិទូបែបរិះគន់មិនបានមើលឃើញភាពសំខាន់ ឬប្រើអំណាចថាជារឿងជៀសមិនរួចនោះទេ។ ពួកគេបានប្រឆាំងនឹងគំរូថ្មីៗនៃការគ្រប់គ្រង និងការសិក្សា ដើម្បីផ្តាច់វដ្តនៃភាពសំខាន់ ឬការប្រើអំណាច។ ពួកគេជឿជាក់ថា គ្រូបង្រៀន និងសាលារៀនអាចជួយបង្កើនញាណនៃមនុស្ស ដែលត្រូវបានគេកេងប្រវ័ញ្ច និងផ្តល់អំណាចឱ្យដកហូតទ្រព្យសម្បត្តិ។ ពួកគេចង់ឱ្យសាលារៀន ក្លាយជាវិស័យសាធារណៈបែបប្រជាធិបតេយ្យ ដែលក្នុងនោះយុវវ័យ ចង់សិក្សា ដើម្បីពង្រោះសីលវិជ្ជានៃសមភាព។

### ច-ដំណើររឿងជីវិតរបស់សិស្ស

ទ្រឹស្តីវិទូបែបរិះគន់ អះអាងថា ចំណេះដឹងស្របច្បាប់ដ៏ពិត និងតម្លៃក្នុងសាលារៀន និងកម្មវិធីសិក្សា ដែលកើតមានឡើងនៅក្នុងសហគមន៍មូលដ្ឋានរបស់សិស្ស ស្ថានភាពក្លាមៗ និងសហគមន៍ដែលគេរស់នៅ និងសាលារៀន

ដែលគេកំពុងសិក្សា។ គ្រូគួរតែចាប់ផ្តើមបង្កើនញាណជាមួយសិស្សក្នុងថ្នាក់រៀនរបស់ខ្លួនតាមការពិនិត្យមើលលក្ខខណ្ឌតាមសហគមន៍អ្នកជិតខាង។ សិស្សអាចបែងចែកដំណើររឿងជីវិតរបស់គេ ដើម្បីបង្កើតស្វ័យជីវប្រវត្តិក្រុមបែបសហការ ដែលរ៉ាយរ៉ាប់បទពិសោធនៅតាមផ្ទះ សាលារៀន និងសហគមន៍។ គេអាចភ្ជាប់ថែមទៀតនូវស្វ័យជីវប្រវត្តិក្រុមនេះ ទៅនឹងដំណើររឿងធំជាងនេះនៃថ្នាក់រៀនសេដ្ឋកិច្ចតាមទស្សនវិស័យ និងក្រុមភាសា ជនជាតិភាគតិច និងជាតិសាសន៍។

សង្គមពហុវប្បធម៌សហរដ្ឋអាម៉េរិកដ៏ពិតប្រាកដ ផ្តល់នូវកំណៃប្រៃថ្មីច្រើនថែមទៀតនូវដំណើររឿងតាមបទពិសោធរបស់ជនជាតិអាម៉េរិក ជាជាងបទពិសោធដែលបានយល់ស្របជាផ្លូវការ។ សមាជិកនៃក្រុមភាសាជនជាតិភាគតិច ពូជសាសន៍ អាចប្រាប់ដំណើររឿងផ្ទាល់ខ្លួនរបស់គេជាជាងឱ្យគេប្រាប់ដំណើររឿងដល់ពួកគេ។ ក្រោយពេលស្រាវជ្រាវរកឃើញអត្តសញ្ញាណផ្ទាល់ខ្លួនរបស់គេ សិស្សអាចអភិវឌ្ឍមធ្យោបាយរបស់គេដើម្បីទទួលស្គាល់លក្ខណៈពិសេសនៃបុគ្គលិកលក្ខណៈ និងការរកឃើញផ្សេងពីភាពពិត និងដើម្បីប្រឆាំងទៅនឹងការអប់រំទាំងក្នុងនិងក្រៅសាលារៀន។ គេអាចសិក្សាពីរបៀបគ្រប់គ្រងជីវិតផ្ទាល់ខ្លួន និងបង្កើតអនាគតផ្ទាល់ខ្លួន[8]។

**២-៣-ការអនុវត្ត សម្រាប់គ្រូប្រចាំថ្នាក់រៀននាពេលសព្វថ្ងៃ**

**ក-គ្រូបង្រៀនត្រូវតែផ្តល់អំណាចដល់ខ្លួន**

ទ្រឹស្តីវិទូបែបរិះគន់ ជំរុញឱ្យគ្រូ៖

១-រកឱ្យឃើញមិត្តពិតប្រាកដរបស់គេជានរណា ស្ថិតក្នុងការតស៊ូ ដើម្បីគ្រប់គ្រងសាលារៀនឱ្យបានជោគជ័យ។

២-សិក្សាថា នរណាជាសិស្សរបស់គេតាមការជួយពួកគេ ដើម្បីសិក្សាឆ្ពោះទៅរកអត្តសញ្ញាណផ្ទាល់ខ្លួនរបស់គេ។

៣-សហការជាមួយប្រជាជននៅមូលដ្ឋានដើម្បីសាលារៀន និងការកែលំអសហគមន៍

៤-ចូលរួមជាមួយនឹងគ្រូ ដែលមានចិត្តដូចគ្នា ក្នុងអង្គការចាត់តាំងវិជ្ជាជីវៈគ្រប់គ្រងដោយគ្រូ ដែលធ្វើការងារដើម្បីកែទម្រង់ការអប់រំដ៏ពិតប្រាកដ។

៥-ចូលរួមនៅក្នុងការសន្ទនាបែបរិះគន់អំពីបញ្ហាអប់រំ សង្គម សេដ្ឋកិច្ច និងនយោបាយដែលប្រឈមមុខនឹងសង្គមអាម៉េរិក។

**ខ-ស្តង់ដា និងការវាយតម្លៃ**

**-ដែនកំណត់ខាងក្រៅស្តីអំពីអំណាចរបស់គ្រូ**

តាមលក្ខណ្ឌធ្វើការងាររបស់គ្រូបែបរិះគន់ ទ្រឹស្តីវិទូបែបរិះគន់រកឃើញឥទ្ធិពល

[8] Christine E. Sleeter and Peter L. Mclaren, eds. *Multicultural Education, Critical Pedagogy, and the Politics of Difference* (Albany: State University of New York Press, 1995).

របស់គ្រូ ក្នុងការកំណត់ជីវភាពវិជ្ជាជីវៈផ្ទាល់ខ្លួនរបស់គេ ដែលត្រូវបានកំណត់ដែនដ៏ជាក់លាក់។ ក្រុមប្រឹក្សារដ្ឋ ដែលមិនមែនជាអង្គការចាត់តាំងវិជ្ជាជីវៈរបស់គ្រូមួយភាគធំ កំណត់ឱ្យការទាមទារចូលទៅជាវិជ្ជាជីវៈ។ នៅពេលដែលសមត្ថភាពសិស្ស តាមតេស្តសមិទ្ធផលសិក្សា តាមស្តង់ដា កំណត់នូវប្រសិទ្ធភាពសាលារៀន និងសមត្ថភាពគ្រូនោះ គ្រូបង្រៀនត្រូវបានវិនិច្ឆ័យ តាមលក្ខណៈវិនិច្ឆ័យ ដែលត្រូវបានប្រគល់អាណត្តិ ដោយអ្នកច្បាប់រដ្ឋ និងត្រូវបានរៀបចំ ដោយអ្នកជំនាញការ ដែលនៅខាងក្រៅសាលារៀន និងថ្នាក់រៀន។

**-បញ្ហាសិទ្ធិប្រើប្រាស់បច្ចេកវិទ្យា**

លោក Michael Apple ជាអ្នកអប់រំដែលបានវិភាគកម្មវិធីសិក្សាពីការតម្រង់ទិសម៉ាក្សស៊ីស្តបែបថ្មីនោះ ព្រមានថា ការពិភាក្សាយ៉ាងច្រើន អំពីបច្ចេកវិទ្យាអប់រំក្នុងថ្នាក់រៀន មានលក្ខណៈជាវោហារសាស្ត្រជាជាងជំរុញចិត្ត សម្រាប់ការផ្លាស់ប្តូរដ៏ពិតប្រាកដ។ គាត់ជឿជាក់ថា បញ្ហាពិតប្រាកដ គោរពគោលបំណងនៃបច្ចេកវិទ្យាអប់រំ។ ប្រសិនបើបច្ចេកវិទ្យាអប់រំមិនបានជួយលាតត្រដាងបញ្ហា ដែលជាឫសគល់នៃភាពដោយឡែកនិងការលើកតម្កើងទ្រឹស្តីវិទូបែបរិះគន់ ដែលមិនសូវសម្បូរនោះ វាទំនងជានឹងនាំបែបបទ ដែលមិនទាន់រៀបចំបានត្រឹមត្រូវ មិនជិតស្និទ្ធ ដែលកើតចេញមកពីផ្នែកខាងក្រៅក្នុងការអប់រំជាជាងបញ្ហាមួយ ដែលកើតចេញពីលក្ខខណ្ឌខាងក្រៅសាលារៀន[៩]។

**-មេរៀនមួយ តាមគោលវិធីទ្រឹស្តីបែបរិះគន់**

គ្រូបង្រៀនដែលប្រើប្រាស់គោលវិធីទ្រឹស្តីបែបរិះគន់ អាចរៀបចំមេរៀន ដែលសម្រាប់សិស្សមុខវិជ្ជាសិក្សាសង្គម នៅអនុវិទ្យាល័យ ស្រាវជ្រាវរកមរតកជនជាតិភាគតិចនិងពូជសាសន៍របស់គេ។ សិស្សចាប់ផ្តើមតាមការបែងចែកចំណាប់អារម្មណ៍របស់គេអំពីមរតកតាមរយៈការនិទានប្រាប់ដំណើររឿងអំពីគ្រួសារ ទំនៀមទម្លាប់ និងការប្រារព្ធពិធីផ្សេងៗ។ បន្ទាប់មក ឪពុកម្តាយ និងជីដូនជីតាត្រូវបានគេអញ្ជើញជាវាគ្មិន ដើម្បីចែករំលែកបទពិសោធ អំពីវប្បធម៌របស់គេជាមួយនឹងសិស្ស។ បន្ទាប់មកទៀតសិស្សអាចប្រតិដ្ឋការបង្ហាញពហុវប្បធម៌ ដែលរាប់បញ្ចូលរូបថតគ្រួសារ វត្ថុគង់នៅពីបុរាណ និងវត្ថុផ្សេងៗទៀត ដែលពន្យល់ពីជីវិត និងវប្បធម៌ នៃមនុស្សដែលរស់នៅក្នុងសហគមន៍មូលដ្ឋាន។

## សន្និដ្ឋាន

ជារួមមក ទ្រឹស្តីអភិវឌ្ឍន៍និយម ជាទ្រឹស្តីមួយ ដែលទទួលបានពីការគាំទ្រពីលោក

[9] Michael W. Apple, *Official Knowledge: Democratic Education in a Conservative Age* (New York and London: Routledge, 2000), pp.132-133.

Dewey, Kilpatrick, Parker និង Johnson នោះ *ជាទ្រឹស្តីអប់រំយ៉ាងសំខាន់មួយ ដែលត្រូវបានគេយកទៅប្រតិបត្តិសម្រាប់ការបង្រៀន ដោយផ្តោតអារម្មណ៍លើលក្ខណៈពិសេសនៃការដោះស្រាយបញ្ហានិងសកម្មភាពនៅក្នុងក្រុមៗ គ្រូដើរតួជាអ្នកសម្របសម្រួលៗ ទ្រឹស្តីរិះគន់និយម ដែលទទួលបានការគាំទ្រពីលោក* McLaren និង Giroux *ជាទ្រឹស្តីអប់រំសំខាន់មួយ ដែលត្រូវបានគេយកទៅប្រតិបត្តិនៅក្នុងវិស័យអប់រំ ដែលថា ការបង្រៀនត្រូវផ្តោតលើទំនាស់សង្គមៗ*

## ឯកសារយោង


1- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2008.

2- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 20011.

3- Arthur Zilversmith, *Changing Schools: Progressive Theory and Practice, 1930-1960*, Chicago: University of Chicago Press, 1993.

4- Lawrence A. Cremin, *The Transformation of the School*, New York: Random Handom House, 1961.

5- Peter W. Airasian and Mary E. Walsh,'' Constructivist Cautions,'' *Phi Delta Kappan*, February 1997.

6- Frank Margonis, "*Marxist, Liberalism, and education Theory, Educational Theory*, Fall 1993.

7- Henry A. Giroux and Peter L. McLaren, eds., *Critical Pedagogy, the State, and Cultural Struggle*, Aldany: State University of New York Press, 1998.

8- Martusewicz and William Reynold, eds., *Inside Out: Contemporary Critical Perspectives in Education*, New York: St. Martin's Press, 1994.

9- Henry A. Giroux and Peter McLaren, eds., *Critical Pedagogy, the State, and Cultural Struggle*, New York: State University of New York Press, 1989.

10- Christine E. Sleeter and Peter L. McLaren, eds. *Multicultural Education, Critical Pedagogy, and the Politics of Difference*, Albany: State University of New York Press, 1995.

11- Michael W. Apple, *Official Knowledge: Democratic Education in a Conservative Age*, New York and London: Routledge, 2000.